ការគោរព
ទំនាក់ទំនង
សិទ្ធិ
ទំនុកចិត្ត
សេចក្តីថ្លៃថ្នូរ
សហគមន៍

# ក្រុមហ៊ុន កូកា-កូឡា និងសិទ្ធិមនុស្ស

## អ្វីដែលអ្នកដឹកនាំទាំងអស់ត្រូវដឹង និងធ្វើ

The Coca-Cola Company

## ការប្តេជ្ញាចិត្តរបស់យើងដើម្បីគោរពសិទ្ធិមនុស្ស

ក្រុមហ៊ុន កូកា-កូឡា យកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាសិទ្ធិមនុស្ស។ ភាពជោគជ័យនៃក្រុមហ៊ុនរបស់យើងត្រូវបានបង្កើតឡើងតាមស្តង់ដារខ្ពស់ដោយផ្តោតលើគុណភាពសុចរិតភាព និងឧត្តមភាព។ ក្រុមហ៊ុនរំពឹងថាស្តង់ដារទាំងនេះត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ចំពោះការគោរពលើសិទ្ធិមនុស្ស។

ខិត្តប័ណ្ណនេះត្រូវបានផ្តល់ជូនដើម្បីជួយណែនាំក្នុងការងារប្រចាំថ្ងៃសំរាប់ខ្លួនអ្នកផ្ទាល់ និងសំរាប់សកម្មភាពការងារដោយរួមបញ្ចូល គោលនយោបាយសិទ្ធិមនុស្សរបស់ក្រុមហ៊ុន ទាំងក្នុងសកម្មភាពផ្ទាល់ខ្លួន ហើយក្នុងនាមជាអ្នកដឹកនាំ អ្នកត្រូវប្តេជ្ញាចិត្តធានាអោយបាននូវការអនុវត្តន៍ការគោរពសិទ្ធិមនុស្ស សំរាប់ក្រុមការងាររបស់អ្នក។ យើងឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់យើងក្នុងការគោរពសិទ្ធិមនុស្សនៅគ្រប់ទិដ្ឋភាពទាំងអស់នៃអាជីវកម្មដែលវាជាផ្នែកមួយនៃវិធីធ្វើការយ៉ាងសាមញ្ញរបស់យើង។

## ដូច្នេះអ្វីដែលត្រូវរំពឹងទុក?

- ធ្វើឱ្យមានការគោរពសិទ្ធិមនុស្សដោយស្របតាមគោលនយោបាយសិទ្ធិមនុស្សរបស់យើងដែលជាផ្នែកមួយនៃវិធីដែលអ្នកធ្វើការ។ អាចនិយាយម្យ៉ាងទៀតបានថា ជាការអនុវត្តជាក់ស្តែង "និយាយអ្វីត្រូវធ្វើនឹង"។ រក្សាសិទ្ធិមនុស្សជាស្នូលសំខាន់សំរាប់ការប្រជុំជាក្រុមរបស់អ្នក និងបង្ហាញពីអ្វីដែលហៅថា «ការគោរព» តាមរយៈអាកប្បកិរិយាផ្ទាល់ខ្លួនរបស់អ្នក។

- គោលនយោបាយសិទ្ធិមនុស្សត្រូវអនុវត្តទាំងក្នុង និងក្រៅក្រុមហ៊ុន។ នៅពេលចូលរួមជាមួយអ្នកផ្គត់ផ្គង់ អតិថិជន សហគមន៍ និងក្រុមការងារដទៃទៀតដែលពួកគេអាចរងផលប៉ះពាល់ដោយសារអ្វីដែលយើងប្រព្រឹត្តិ (ឬសូម្បីតែអ្វីដែលយើងមិនប្រព្រឹត្តិ)
យើងត្រូវតែអនុវត្តស្តង់ដារសិទ្ធិមនុស្សដូចគ្នាទៅនឹងការអនុវត្តជាមួយក្រុមការងាររបស់អ្នកដែរ។

- ចំពោះដំណើរការអាជីវកម្មថ្មី ការទិញ ឬសកម្មភាពថ្មីណាមួយ សូមអនុវត្តកិច្ចការទាំងនោះដោយផ្តោតទៅលើសិទ្ធិមនុស្ស។ ជាទូទៅហៅថាការអង្កេតដែលអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់។ មធ្យោបាយដ៏ល្អបំផុតដើម្បីចៀសវាងការរំលោភសិទ្ធិមនុស្សគឺត្រូវធានាអោយបានថាគោលការណ៍សិទ្ធិមនុស្សត្រូវបានអនុវត្តតាំងពីការចាប់ផ្តើម និងបន្តផ្តោតការយកចិត្តទុកដាក់ទាំងក្នុងអំឡុងពេលនៃដំណើរការ ការទិញ ឬសកម្មភាពនានា។

- ប្រសិនបើអ្នកចូលរួមក្នុងបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់ ឬទាក់ទងជាមួយអ្នកលក់ណាមួយ អ្នកត្រូវប្រាកដថាអ្នកអនុវត្តតាម គោលការណ៍ណែនាំអ្នកផ្គត់ផ្គង់ ដែលស្របតាមគោលនយោបាយសិទ្ធិមនុស្សរបស់ក្រុមហ៊ុន។

- ហានិភ័យអំពីសិទ្ធិមនុស្សអាចកើតមានឡើងនៅក្នុងប្រទេសណាមួយ និងបរិបទណាមួយ។ ក្នុងនាមជាអ្នកដឹកនាំ អ្នកត្រូវទទួលយកនូវហានិភ័យថ្មីៗ ឬការកើតមានហានិភ័យសិទ្ធិមនុស្ស និងរាយការណ៍អំពីបញ្ហាទាំងនោះតាមរយៈបណ្តាញខាងក្នុងនានា។ សិទ្ធិមនុស្សជារឿងសំខាន់ហើយប្រតិបត្តិការអាចមានឥទ្ធិពលដល់សិទ្ធិមនុស្សណាមួយ ឬច្រើនទាំងក្នុង និងក្រៅក្រុមហ៊ុន។

- ចាត់វិធានការ "ត្រៀមខ្លួនជាមុន" ដើម្បីគ្រប់គ្រងស្ថានភាព។ ប្រសិនបើអ្នកសង្ស័យថាមានករណីអំពីការរំលោភសិទ្ធិមនុស្ស អ្នកត្រូវរាយការណ៍ជាបន្ទាន់។ ការរាយការណ៍អាចធ្វើឡើងដោយផ្ទាល់តាមរយៈអ្នកគ្រប់គ្រងថ្នាក់លើ ផ្នែកធនធានមនុស្ស ទីប្រឹក្សាផ្នែកច្បាប់ ឬ ផ្នែកក្រមសីលធម៌របស់ក្រុមហ៊ុន។

- ស្រដៀងគ្នានេះដែរ ប្រសិនបើមានការដាក់ពាក្យបណ្តឹងមកអ្នក សូមអនុវត្តឱ្យបានតឹងរ៉ឹង និងធ្វើការជាមួយផ្នែកធនធានមនុស្សដើម្បីចាប់ផ្តើមធ្វើការស៊ើបអង្កេត។ ប្រសិនបើគណៈគ្រប់គ្រងកំណត់ចាំបាច់ថាត្រូវតែមានសកម្មភាពកែតម្រូវ សូមអនុវត្ត និងចាត់វិធានការជាបន្ទាន់ ដោយផ្អែកលើគោលការណ៍ណែនាំដែលផ្តល់ជូនដោយផ្នែកធនធានមនុស្ស និង/ឬ ផ្នែកច្បាប់។

- ភាពស៊ីសង្វាក់គ្នាមានសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយសិទ្ធិមនុស្សរបស់ក្រុមហ៊ុន។ ប្រសិនបើអ្នកមិនច្បាស់អំពីសិទ្ធិណាមួយ នៅក្នុងស្ថានភាពណាមួយ សូមប្រឹក្សាជាមួយក្រុមសិទ្ធិការងារជាសកល តាមរយៈ humanrights@coca-cola.com *មុននឹង* ចាត់វិធានការណាមួយ។

- លើកទឹកចិត្តក្រុមការងាររបស់អ្នកឱ្យប្រុងប្រយ័ត្នចំពោះហានិភ័យសិទ្ធិមនុស្ស និងជំរុញឱ្យមានបរិយាកាសមួយដែលកង្វល់ទាំងនោះ អាចត្រូវបានចែករំលែកដោយសេរី និងភ្លាមៗព្រមទាំងដោះស្រាយបានដោយត្រឹមត្រូវ។

- ទាញយកកម្មវិធីសិទ្ធិមនុស្សរបស់ក្រុមហ៊ុន កូកា-កូឡា (តាមរយៈ KO App Store) ដែលជាឧបករណ៍ដើម្បីជួយអ្នកនិងក្រុមការងារក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យអំពីបញ្ហាសិទ្ធិមនុស្ស។

- ប្រើប្រាស់ធនធានសិទ្ធិមនុស្សរបស់ក្រុមហ៊ុនរួមទាំងគោលនយោបាយសិទ្ធិមនុស្ស គោលការណ៍ណែនាំអ្នកផ្គត់ផ្គង់បញ្ជីត្រួតពិនិត្យលើការអង្កេត ការងារសិទ្ធិមនុស្ស អនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់ ការណែនាំអំពីការអនុវត្តន៍ និងធនធានផ្សេងៗទៀតដែលមាននៅក្នុងក្រុមហ៊ុន៖
    - http://www.coca-colacompany.com/our-company/human-rights-policy
    - http://www.coca-colacompany.com/our-company/supplier-guiding-principles

ចំពោះសំណួរ ឬព័ត៌មានបន្ថែម សូមអ៊ីម៉ែលមកកាន់៖
humanrights@coca-cola.com

The Coca-Cola Company

ការគោរព
ទំនាក់ទំនង
សិទ្ធិ
ទំនុកចិត្ត
សេចក្តីថ្លៃថ្នូរ
សហគមន៍

# គោលនយោបាយសិទ្ធិមនុស្ស

## គោលនយោបាយសិទ្ធិមនុស្ស

ការគោរពសិទ្ធិមនុស្សគឺជាតម្លៃជាមូលដ្ឋានរបស់ក្រុមហ៊ុន Coca-Cola។ យើងខិតខំគោរព និងលើកកម្ពស់សិទ្ធិមនុស្សស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិលើអាជីវកម្ម និងសិទ្ធិមនុស្សក្នុងទំនាក់ទំនងរបស់យើងជាមួយនិយោជិត អ្នកផ្គត់ផ្គង់ និងអ្នកច្រកដបឯករាជ្យរបស់យើង។ គោលបំណងរបស់យើងគឺដើម្បីជួយបង្កើនការគោរពសិទ្ធិមនុស្សនៅក្នុងសហគមន៍ដែលយើងធ្វើប្រតិបត្តិការ។

គោលនយោបាយនេះត្រូវបានដឹកនាំដោយគោលការណ៍សិទ្ធិមនុស្សអន្តរជាតិដែលគ្របដណ្តប់ដោយសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស រួមទាំងសេចក្តីព្រាងដែលមានចែងក្នុងច្បាប់សិទ្ធិអន្តរជាតិ និងសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិឆ្នាំ 1998 ស្តីពីគោលការណ៍មូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ។

គោលនយោបាយនេះអនុវត្តចំពោះក្រុមហ៊ុន Coca-Cola អង្គភាពនានាដែលយើងកាន់កាប់ អង្គភាពដែលមានចំណែករបស់យើង និងកន្លែងដែលយើងគ្រប់គ្រង។ ក្រុមហ៊ុនក៏រំពឹងផងដែរថា អ្នកច្រកដបឯករាជ្យ និងអ្នកផ្គត់ផ្គង់នឹងគាំទ្រគោលការណ៍ទាំងនេះ ហើយជំរុញឱ្យពួកគេអនុវត្តគោលនយោបាយស្រដៀងគ្នានៅក្នុងអាជីវកម្មរបស់ពួកគេផ្ទាល់។

យើងប្រើការស៊ើបអង្កេតមុនចុះកិច្ចសន្យាជាមធ្យោបាយមួយដើម្បីកំណត់ និងទប់ស្កាត់ហានិភ័យសិទ្ធិមនុស្សដល់អ្នកដែលនៅក្នុងអាជីវកម្ម និងដៃគូរបស់យើង។ នៅត្រង់ចំណុចដែលយើងបានកំណត់អត្តសញ្ញាណផលប៉ះពាល់អវិជ្ជមាននៃសិទ្ធិមនុស្សជាលទ្ធផលពី ឬបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់យើង យើងប្តេជ្ញាផ្តល់ ឬសហប្រតិបត្តិការក្នុងការកែបំបាត់ដោយយុត្តិធម៌ និងសមធម៌របស់ពួកគេ។ យើងស្វែងរកការលើកកម្ពស់លទ្ធភាពទទួលបានការជួសជុលដែលយើងត្រូវបានផ្សារភ្ជាប់ ឬចូលរួមផលប៉ះពាល់អវិជ្ជមានទាំងនោះតាមរយៈទំនាក់ទំនងរបស់យើងជាមួយភាគីទីបី។

គោលនយោបាយសិទ្ធិមនុស្សត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន Coca-Cola រួមទាំងនាយកប្រតិបត្តិផងដែរ។

## ការចូលរួមរបស់សហគមន៍ និងកូនហ៊ុន

យើងទទួលស្គាល់ថា យើងគឺជាផ្នែកមួយនៃសហគមន៍ដែលយើងធ្វើប្រតិបត្តិការ។ យើងចូលរួមជាមួយសហគមន៍ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សដែលមានសារៈសំខាន់ ចំពោះពួកគេ ដូចជាសិទ្ធិដីធ្លី ការចូលប្រើប្រាស់ទឹក និងបញ្ហាសុខភាព ជាដើម។ យើងក៏ចូលរួមជាមួយប្រជាជននៅក្នុងសហគមន៍ទាំងនោះផងដែរ រួមទាំងជនជាតិដើមភាគតិចក៏ដូចជាក្រុមងាយរងគ្រោះ និងក្រុមខ្វះខាតផ្សេងៗទៀត។ គោលបំណងរបស់យើងគឺធានាបាន តាមរយៈការពិភាក្សាដែលយើងកំពុងស្តាប់ កំពុងស្វែងយល់ពី និងពិចារណាទស្សនៈរបស់ពួកគេ នៅពេលដែលយើងធ្វើអាជីវកម្មរបស់យើង។ យើងជឿថា បញ្ហាក្នុងតំបន់ត្រូវបានដោះស្រាយដោយសមរម្យបំផុតនៅថ្នាក់មូលដ្ឋាន។

នៅទីណាដែលសមស្រប យើងចូលរួមជាមួយសង្គមស៊ីវិល និងភាគគីពាក់ព័ន្ធនានាអំពីបញ្ហាសិទ្ធិមនុស្សដែលទាក់ទងទៅនឹងអាជីវកម្មរបស់យើង។ ការនេះរួមបញ្ចូលទាំងបញ្ហានៅក្នុងក្រុមហ៊ុនរបស់យើង នៅទូទាំងសង្វាក់តម្លៃរបស់យើង និងជាមួយការឧបត្ថម្ភផ្សេងៗរបស់យើង តាមរយៈការដែលយើងស្វែងរកដើម្បី លើកកម្ពស់ការគោរពសិទ្ធិមនុស្ស។

## ភាពចម្រុះ និងការបញ្ចូល

យើងផ្តល់តម្លៃ និងជំរុញភាពចម្រុះ និងការបញ្ចូលមនុស្សដែលយើងធ្វើការជាមួយ។ យើងប្តេជ្ញាផ្តល់ឱកាសស្មើគ្នា និងមិនអត់ឱនចំពោះការរើសអើង និងការយាយីណាមួយឡើយ។ យើងធ្វើការដើម្បីថែទាំកន្លែងធ្វើការដែលមិនមានការរើសអើង ឬការយាយីលើមូលដ្ឋាននៃពូជសាសន៍ ភេទ ពណ៌សម្បុរ ប្រភពជនជាតិ ឬសង្គម ជនជាតិភាគតិច សាសនា អាយុ ពិការភាព ទំនោរផ្លូវភេទ អត្តសញ្ញាណ ឬការបង្ហាញយែនឌ័រ និន្នាការនយោបាយ ឬស្ថានភាពណាមួយផ្សេងទៀតដែលត្រូវបានការពារដោយច្បាប់ជាធរមាន។ មូលដ្ឋានសម្រាប់ការជ្រើសរើសបុគ្គលិកថ្មី ការជួល ការដាក់ជំនួស ការអភិវឌ្ឍ ការបណ្តុះបណ្តាល ការផ្តល់សំណង និងការតម្លើងតំណែងនៅក្រុមហ៊ុនគឺជាគុណសម្បត្តិ លទ្ធផលនៃការបំពេញការងារ ជំនាញ និងបទពិសោធន៍។

យើងមិនអត់អោននឹងអាកប្បកិរិយាមិនគោរព ឬភាពមិនសមរម្យ ការប្រព្រឹត្តអយុត្តិធម៌ ឬការសងសឹកគ្រប់ប្រភេទ។ ការបៀតបៀនមិនត្រូវបានអត់ឱនឱ្យនៅកន្លែងធ្វើការ និងក្នុងករណីដែលទាក់ទងនឹងការងារណាមួយក្រៅពីកន្លែងធ្វើការឡើយ។

## សេរីភាពខាងសមាគមន៍ និងការចរចារជាសមូហភាព

យើងគោរពសិទ្ធិរបស់និយោជិតរបស់យើងក្នុងការចូលរួម បង្កើត ឬមិនចូលរួមក្នុងសហជីពពលកម្មដោយគ្មានការភ័យខ្លាចនិងការសងសឹក ការបំភិតបំភ័យ ឬការបៀតបៀនឡើយ។ កន្លែងដែលនិយោជិតត្រូវបានតំណាងដោយសហជីពដែលទទួលស្គាល់ដោយស្របច្បាប់ យើងប្តេជ្ញាបង្កើតកិច្ចសន្ទនាប្រកបដោយការស្តាបនាជាមួយតំណាងដែលបានជ្រើសរើសដោយសេរីរបស់ពួកគេ ។ ក្រុមហ៊ុនមានការប្តេជ្ញាចិត្តក្នុងការចរចារឱ្យបានល្អជាមួយតំណាងបែបនេះ។

## កន្លែងធ្វើការមានសុវត្ថិភាព និងសុខុមាលភាពល្អ

សុវត្ថិភាព និងសុខុមាលភាពរបស់និយោជិតរបស់យើងគឺមានសារៈសំខាន់បំផុត។ គោលនយោបាយរបស់យើងគឺដើម្បីផ្តល់នូវកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងមានសុខុមាលភាពល្អ និងអនុលោមតាមច្បាប់ និងបទបញ្ជាសុវត្ថិភាព ព្រមទាំងសុខុមាលភាពក៏ដូចជាតម្រូវការរបស់បទបញ្ជាផ្ទៃក្នុង។ ដោយមានការពិគ្រោះយោបល់ជាមួយនិយោជិតរបស់យើង យើងធ្វើការ ផ្តល់ និងរក្សាកន្លែងធ្វើការឱ្យមានសុវត្ថិភាព សុខុមាលភាពល្អ និងមានផលិតភាព តាមរយៈការដោះស្រាយ និងធ្វើការកែបំបាត់ហានិភ័យនៃគ្រោះថ្នាក់ ការរងរបួស និងផលប៉ះពាល់សុខភាពដែលបានដឹងជាមុន។

## សន្តិសុខនៅកន្លែងការងារ

យើងប្តេជ្ញារក្សាកន្លែងការងារឱ្យគ្មានអំពើហិង្សា ការបៀតបៀន ការបំភិតបំភ័យ និងស្ថានភាពគ្មានសុវត្ថិភាព ឬលក្ខខណ្ឌរាំងស្ទះផ្សេងទៀត ដោយសារតែការគំរាមកំហែងខាងក្នុង និងខាងក្រៅ។ ការការពារសុវត្ថិភាពសម្រាប់និយោជិតត្រូវបានផ្តល់ជូនតាមតម្រូវការ និងត្រូវបានរក្សាទុកដោយគោរពតាមភាពជាឯកជន និងសេចក្តីថ្លៃថ្នូររបស់និយោជិត។

## ពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស

យើងហាមឃាត់ការប្រើប្រាស់ពលកម្មដោយបង្ខំគ្រប់ទម្រង់ទាំងអស់ ក្នុងនោះរួមមានពលកម្មនៅពន្ធនាគារ ពលកម្មដែលជាប់កិច្ចសន្យា ពលកម្មដែលជាទាសភាព ពលកម្មយោធា ទម្រង់ទំនើបនៃទាសភាព និងការជួញដូរមនុស្សគ្រប់ទម្រង់។

## ពលកម្មកុមារ

យើងហាមឃាត់ការជួលបុគ្គលម្នាក់ៗដែលមានអាយុក្រោម 18 ឆ្នាំសម្រាប់មុខតំណែងដែលការងារគ្រោះថ្នាក់ត្រូវបានតម្រូវ។

## ម៉ោងធ្វើការ ប្រាក់ឈ្នួល និងអត្ថប្រយោជន៍

យើងផ្តល់ អត្ថប្រយោជន៍ដល់បុគ្គលិកដែលមានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារការងារ និងទីផ្សារការងារក្នុងស្រុក និងអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងចរចារជាសមូហភាព។ យើងធ្វើការដើម្បីធានាឱ្យបាននូវការប្រតិបត្តិទាំងស្រុងតាមច្បាប់ដែលត្រូវអនុវត្តទាក់ទងនឹងប្រាក់ឈ្នួល ម៉ោងធ្វើការ ម៉ោងបន្ថែម និងអត្ថប្រយោជន៍ផ្សេងៗ។

## សិទ្ធិដីធ្លី និងធនធានទឹក

យើងទទួលស្គាល់នូវការអនុវត្តដែលគួរឱ្យកត់សម្គាល់ទាក់ទងនឹងការគោរពសម្រាប់សិទ្ធិមនុស្សថា ការប្រើប្រាស់ដី និងការប្រើប្រាស់ទឹកនៅគ្រប់សាខារបស់យើងដែលអាចកើតមាន ដែលយើងដោះស្រាយតាមរយៈគោលនយោបាយ និងសកម្មភាពជាក់លាក់។

ខណៈពេលយើងមិនទិញគ្រឿងផ្សំដោយផ្ទាល់ពីកសិដ្ឋាននានា ដោយផ្អែកលើគុណតម្លៃរបស់យើងដែលយើងជាអ្នកទិញ ផលិតផលកសិកម្មនានាដ៏សំខាន់ម្នាក់ យើងត្រូវបង្ខំចិត្តរបសយើងក្នុងការចាត់វិធានការ និងប្រើប្រាស់ឥទ្ធិពលរបស់យើងដើម្បីជួយការពារសិទ្ធិដីធ្លីរបស់កសិករ និងសហគមន៍ក្នុងតំបន់។

យើងគោរពតម្រូវការរបស់មនុស្សសម្រាប់ការផ្គត់ផ្គង់ទឹកដែលមាននិរន្តរភាព ទឹកស្អាត និងការការពារប្រព័ន្ធអេកូឡូហ្ស៊ី និងសហគមន៍តាមរយៈអនាម័យត្រឹមត្រូវ។ តាមរយៈកម្មវិធីគ្រប់គ្រងទឹករបស់យើង យើង បន្តអនុវត្តវិធីសាស្ត្រទាក់ទងនឹងសិទ្ធិនៃការទទួលបានទឹក ដែលកាត់បន្ថយហានិភ័យតាមរយៈការវាយតម្លៃពីហានិភ័យទឹកនៅក្នុងតំបន់ ពិគ្រោះយោបល់ និងធ្វើការជាដៃគូជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីបង្កើតដំណោះស្រាយទៅលើទឹក នៅតាមកន្លែង និងនៅពេលដែលត្រូវការ ហើយក៏បានអនុវត្តផែនការការពារ ប្រភពទឹកនៅកន្លែងរបស់យើងផងដែរ។

## ការរស់នៅមានសុខភាពល្អ

យើងប្តេជ្ញាផ្តល់ព័ត៌មានអាហារូបត្ថម្ភដែលប្រកបដោយតម្លាភាព និង ជម្រើសនៃភេសជ្ជៈនានាដើម្បីអនុញ្ញាតឱ្យអតិថិជនបានយល់ដឹងអំពីជំរើសរបស់គេ ដែលសមស្របជាមួយនឹងរបៀបរស់នៅដែលមានសុខភាពល្អ។

## មានសំណួរ ឬកង្វល់ឬ?

- សូមលើកសំណួរ ឬកង្វល់ណាមួយជាមួយអ្នកគ្រប់គ្រងក្នុងតំបន់ ធនធានមនុស្ស នាយកដ្ឋានច្បាប់ ឬសន្តិសុខជាយុទ្ធសាស្ត្រ
- និយោជិតក៏អាចរាយការណ៍ពីការរំលោភបំពានគោលនយោបាយដែលសង្ស័យផងដែរតាមរយៈគេហទំព័រអ៊ីនធឺណិតដែលមានសុវត្ថិភាព EthincsLine នៅ www.KOethics.com ឬដោយហៅទូរស័ព្ទដោយឥតគិតថ្លៃទៅលេខ ដែលមានសម្រាប់ទីតាំងរបស់ពួកគេ ដែលលេខទូរស័ព្ទនេះអាចរកឃើញនៅលើគេហទំព័រ

សម្រាប់បុគ្គលម្នាក់ៗនៅក្នុងសហភាពអឺរ៉ុប៖ សូមចំណាំថា ដោយសារតែច្បាប់ EU សេវាទូរស័ព្ទ ឬវិបរបស់ EthicsLine អនុញ្ញាតតែសម្រាប់ការរាយការណ៍ពីបញ្ហាហិរញ្ញវត្ថុ គណនេយ្យ និងសាវនកម្មប៉ុណ្ណោះ។ ដើម្បីរាយការណ៍បញ្ហានានានៅក្រោមគោលនយោបាយសិទ្ធិមនុស្ស និងសិទ្ធិនៅកន្លែងធ្វើការ សូមទាក់ទងទៅផ្នែកគ្រប់គ្រងក្នុងតំបន់របស់អ្នក ផ្នែកធនធានមនុស្ស ការិយាល័យមេធាវីមូលដ្ឋាន ឬផ្នែកច្បាប់។

*ក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការកែប្រែគោលនយោបាយនេះនៅគ្រប់ពេលវេលា។ គ្មានអ្វីនៅក្នុងគោលនយោបាយនេះនិយាយ ឬបង្កប់ន័យថា កិច្ចសន្យាដែលមានរវាងក្រុមហ៊ុន និងនិយោជិតរបស់ខ្លួន ឬការចូលរួមក្នុងកម្មវិធីនេះគឺជាការធានាលើការបន្តការងារជាមួយនឹងក្រុមហ៊ុន Coca-Cola ឡើយ។*

ចំពោះសំណួរ ឬព័ត៌មានបន្ថែម សូមអ៊ីម៉ែលមកកាន់៖ humanrights@coca-cola.com

ខែសីហា ឆ្នាំ 2017

The Coca-Cola Company